# បុគ្គលិកសង្គម

**តើអ្នកមានចំណាប់អារម្មណ៍ធ្វើការ ដើម្បីជួយដល់យុវជនដែលបាត់បង់ឱកាស និងក្រុមគ្រួសារពួកគាត់ដែរឬទេ? តើអ្នកចង់ធ្វើការជាមួយក្រុមអ្នកជំនាញ ដែលផ្ដល់នូវសេវាសង្គមប្រកបដោយគុណភាពខ្ពស់ដែរឬទេ? បើមានចំណាប់អារម្មណ៍ អ្នកអាចមកចូលរួមជាមួយយើងបាន!**

អ្នកនឹងចូលរួមជាមួយក្រុមការងាររបស់អង្គការមិត្តសំឡាញ់ ដែលមានអ្នកជំនាញជាង ១២០នាក់ ធ្វើការជាមួយគ្នា ដើម្បីផ្ដល់នូវ សេវាសង្គមជាច្រើនទៅដល់កុមារ និងយុវវ័យដែលបាត់បង់ឱកាស និងក្រុមគ្រួសាររបស់ពួកគេ។ យើងបានបង្កើតវិធីសាស្ត្ររួម មួយចំនួន ដើម្បីគាំទ្រឲ្យកុមារត្រឡប់ទៅរស់នៅជាមួយក្រុមគ្រួសារ និងបន្តការសិក្សារបស់ពួកគេវិញ ធានាក្នុងការផ្ដល់ការបណ្ដុះបណ្ដាលជំនាញ ឬការងារ ទៅពួកគាត់ រួមទាំងការគាំទ្រគ្រួសារ និងសហគមន៍ ក្នុងការជួយថែទាំកូនរបស់គាត់។ យើងបានផ្ដល់ការបណ្ដុះបណ្ដាលជំនាញជាច្រើនដូចជា ចុងភៅ និងសេវាកម្ម សម្អាងកាយ កាត់សក់ ផ្សារដែក អគ្គិសនី។

**តើអ្នកត្រូវធ្វើអ្វី?**

ក្នុងតួនាទីជា **បុគ្គលិកសង្គម** អ្នកនឹងទទួលខុសត្រូវក្នុងការផ្ដល់ការថែទាំកុមារ និងយុវវ័យ ដែលស្នាក់នៅរយៈពេលខ្លីនៅក្នុងមណ្ឌលប្រកបដោយសន្តិសុខ និងសុវត្ថិភាព គ្រប់គ្រងករណីនីមួយៗ និងជួយគាំទ្រពួកគេក្នុងការធ្វើសមាហរណកម្មទៅកាន់សហគមន៍របស់ពួកគេវិញ។

**អ្នកនឹងទទួលខុសត្រូវការងារសំខាន់ៗដូចខាងក្រោម៖**

- ផ្ដល់ការថែកុមារ និងយុវវ័យដែលកំពុងស្នាក់នៅមណ្ឌលអោយមានសន្តិសុខ និងសុវត្ថិភាពស្របតាមស្តង់ដារ
- រៀបចំកម្មវិធីអប់រំ កម្សាន្តសប្បាយ និងកីឡាសម្រាប់កុមារ និងយុវវ័យ
- ផ្ដល់ការគាំទ្រទៅដល់កុមារ និងយុវវ័យតាមការចាំបាច់នានាដូចជា ការប្រឹក្សាយោបល់ សេវាវេជ្ជសាស្ត្រ សេវាច្បាប់
- គ្រប់គ្រងករណី និងសហការជាមួយបុគ្គលិកសង្គមផ្សេងទៀតដើម្បីរៀបចំ និងធ្វើផែនការសមាហរណកម្ម
- ថែទាំមណ្ឌលអោយមានអនាម័យ និងរបៀបរៀបរយ

**យើងត្រូវការអ្នកដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម៖**

- អ្នកមានបរិញ្ញាបត្រសង្គមវិទ្យា ឬចិត្តវិទ្យាកាន់តែប្រសើរ
- អ្នកមានចំណេះដឹងផ្នែកការងារសង្គម ឬការការពារកុមារ
- បទពិសោធន៍ពាក់ព័ន្ធ ០២ឆ្នាំជាមួយការថែទាំកុមារ ឬយុវវ័យ គ្រួសារ និងសហគមន៍
- អ្នកចូលចិត្តធ្វើការងារជាមួយកុមារ/យុវវ័យ និង ការងារសង្គម
- អ្នកមានមានជំនាញក្នុងការទំនាក់ទំនង អាចធ្វើការងារជាក្រុម មានភាពអត់ធ្មត់ ចេះបត់បែន
- អ្នកមានអាយុចាប់ពី៣០ឆ្នាំឡើងទៅ

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមផ្ញើរនូវប្រវត្តិរូបសង្ខេប (CV និង Cover Letter) មកទីស្នាក់ការអង្គការមិត្តសំឡាញ់ អាស័យដ្ឋានផ្ទះលេខ២១៥ ផ្លូវលេខ១៣ ខាងជើងសារៈមន្ទីរជាតិ ឬ E-mail: hr@mithsamlanh.org។ **សូមបញ្ជាក់ពីតួ**

**នាទីដែលអ្នកចង់ដាក់ពាក្យ និងប្រាក់បៀវត្សរ៍ពឹងទុក។** ព័ត៌មានបន្ថែមអាចទំនាក់ទំនងបានតាមរយៈទូរស័ព្ទ ០២៣ ២២០ ៥៩៦។

បេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងត្រូវទំនាក់ទំនងដើម្បីធ្វើការសម្ភាសន៍។ បេក្ខជនទាំងអស់នឹងត្រូវផែកប្រវត្តិរូប ដើម្បីអនុលោមតាមគោលការណ៍ កិច្ចការពារប្រឆាំងនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ(PSEA)។

ទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី**១៧ ខែកុម្ភៈ ឆ្នាំ២០២៤**។